# ការសំភាសន៍របស់អ៊ុំស្រី គឹម លាង

កៈ អ្នកដែរសំភាសន៍គេ ជាង ស៊ីអ៊ារ ខៈ អ្នកដែរអោយគេសំភាសន៍ គឹម លាង

## ការសង្ខេបប្រវត្តិរបស់ អ៊ុំស្រី គឹម លាង

អ៊ុំស្រី គឹម លាង មានអាយុ64ឆ្នាំ នៅឆ្នាំ2018 អ៊ុំស្រី គឹម លាង មានភេទស្រី អ៊ុំស្រី គឹម លាង មានទីលំនៅបច្ចុប្បន្ននៅភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខ័ណ្ឌមានជ័យ នៅរាជធានីភ្នំពេញ។

កៈ ចឹងជាដំបូងខ្ញុំអរគុណអ៊ុំដែរបានអោយខ្ញុំពិភាក្សាពីប្រវត្តិរបស់អ៊ុំ ហើយការសំភាសន៍មួយនេះត្រូវបានរៀបចំដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាមានគោលបំណងចង់រក្សាពីប្រវត្តិរបស់ប្រជាជនខ្មែរ ដើម្បីអោយពួកគាត់ បានស្គាល់ពីប្រវត្តិរបស់ឪពុកម្ដាយនឹង ប្រវត្តិរបស់ដូនតាចឹងនៅពេលដែរខ្ញុំបានសំភាសន៍អ៊ុំ ហើយនឹងខ្ញុំនឹងដាក់ការសំភាសន៍ទាំងអស់នឹងទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងសំរាប់អ៊ុំយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ មួយនឹងទៅក្នុងវេបសាយរបស់សាលាដែរទេអ៊ុំ?

ខៈ អ៊ុំអត់ដឹងដែរកូនអើយ អត់បានសូរកូនចៅចឹងខ្លាចកូនចៅបន្ទោសអ៊ុំចឹងហាស

កៈ អត់អីទេអ៊ុំមួយនឹងគ្រាន់តែទុកអោយពួកគាត់បានស្គាល់នឹងបានដឹងតើអ៊ុំ?

ខៈ ចាំ!!អ៊ុំមិនសូវបានចងចាំប្រវត្តិដូចអ្វីដែរអ៊ុំនិយាយចឹង

កៈ បាទអ៊ុំបាទ?

ខៈ អ៊ុំជំលាសខ្លួនទៅកម្ពុជាក្រោមហោស ហើយដល់ពេលដែរអ៊ុំមានគ្រួសារទៅគ្រួសាររបស់អ៊ុំនឹង បានជំលាសទៅណុងធ្លប់បានធ្វើទាហ៊ាននៅជំនាន់ណុង

កៈ បាទអ៊ុំបាទ ចឹង?

ខ៖  នៅជំនាន់លុនណុលនឹងហាស

ក៖  ចឹងប្រហែលជាខ្ញុំ?

ខ៖  ចឹងដល់ពេលដែរគាត់ស្លាប់ចឹងទៅអត់សូវដឹងប្រវត្តិទេ

ក៖  បាទអ៊ុំបាទនឹងចឹងប្រហែលជា?

ខ៖  ខ្ញុំដឹងតែត្រួសៗៗទេណាស់

ក៖  បាទអ៊ុំត្រូវហើយអ៊ុំ?

ខ៖  ចា៎!!នឹងហើយ

ក៖  បាទអ៊ុំបាទចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍អ៊ុំខ្ញុំមានឈ្មោះថា ជាង ស៊ីអារ ហើយថ្ងៃខែដែរខ្ញុំបានសំភាសន៍អ៊ុំគឺនៅថ្ងៃទី26ខែ3 ឆ្នាំ2018 ចឹងភូមិនឹងអ៊ុំអត់ស្គាល់ទេណាអ៊ុំ?

ខ៖  គេហៅថាភូមិត្នោតជ្រុំ

ក៖  ភូមិត្នោតជ្រុំហីអ៊ុំ?

ខ៖  ចា៎!!នឹងហើយនៅត្នោតជ្រុំ2

ក៖  នៅភូមិត្នោតជ្រុំ2 ចុះសង្កាត់អីគេដែរអ៊ុំ?

ខ៖  នឹងនៅសង្កាត់បឹងទំពុនណាស់

ក៖  នៅសង្កាត់បឹងទំពុន ខ័ណ្ឌមានជ័យ នៅរាជធានីភ្នំពេញណាអ៊ុំ?

ខ៖  ចា៎!!នឹងហើយៗៗនៅសង្កាត់បឹងទំពុន

ក៖  ចឹងសំរាប់អ៊ុំឈ្មោះពេញរបស់អ៊ុំនឹងមានឈ្មោះអីគេដែរអ៊ុំ?

ខ៖  អ៊ុំមានឈ្មោះ គឹម លាង

ក៖  អ៊ុំមានឈ្មោះអ៊ុំ គឹម លាង

ខ៖  ចា៎!!ឈ្មោះគឹម លាងនឹងហាស

ក៖  ចុះបើត្រកូលវិញអ៊ុំត្រកូលអីគេដែរ?

ខ៖  ដាក់ត្រកូលគឹមនឹងតែម្តងនឹង

ក៖  ចឹងឈ្មោះ គឹម លាងចឹងតែម្តងហោសអ៊ុំ?

ខ៖  ចា៎!!នឹងហើយ

ក៖  ចុះកាលពីក្មេងនឹងមាននរណាហៅឈ្មោះអ៊ុំអីក្រៅទេអ៊ុំ?

ខ៖  ចា៎!!អ៊ុំនឹងអត់មាននរណាគេហៅទេ

ក៖  ចឹងហៅតែឈ្មោះគឹម លាងចឹងតែមួយនឹងទេហោស

ខ៖  ចា៎!!ហៅឈ្មោះគឹម លាងនឹងមួយនឹង

ក៖  ចុះចឹងឈ្មោះហៅក្រៅអីអត់មានទេហោសអ៊ុំ?

ខ៖  អត់កូនអត់មានទេ

ក៖  បាទ ចុះសព្វថ្ងៃនឹងអ៊ុំអាយុប៉ុន្មានដែរទៅអ៊ុំ?

ខ៖  អ៊ុំអាយុ64ឆ្នាំហើយនឹងហាស

ក៖  ចឹងអ៊ុំអាយុ64ឆ្នាំហើយណាអ៊ុំ?

ខ៖  ចា៎!!នឹង

ក៖  ចុះអ៊ុំកើតនៅថ្ងៃខែឆ្នាំណាអ៊ុំមានដឹងទេ?

ខ៖  កើតនៅឆ្នាំ1954ចាំចឹងហាសកូន

ក៖  នៅឆ្នាំ1954 ចុះថ្ងៃខែអ៊ុំមានចងចាំទេអ៊ុំ?

ខ៖  ថ្ងៃខែនឹងអ៊ុំអត់មានចងចាំដែរនឹង

ក៖  អូ៎!!បាទអ៊ុំ ចុះថ្ងៃអីខែអីក៏អ៊ុំអត់ចងចាំដែរ?

ខ៖

អត់ទេយើងនៅតូចយើងកើតមកហើយវាមិនបានសួរថ្ងៃអីខែអីផងនឹងធម្មតាយើងកូនអ្នកស្រែចឹង ទៅណាស់

កៈ បាទអ៊ុំបាទត្រូវ?

ខៈ យើងមិនមែនកូនអ្នកក្រុងទេ ដល់ពេលចឹងខ្ញុំមិនសូវចងចាំថ្ងៃខែទេគាត់តែ

កៈ គាត់ចងចាំតែឆ្នាំតែម្ដងនឹងហោសអ៊ុំ?

ខៈ ខ្ញុំចងចាំតែឆ្នាំ ថ្ងៃខែនឹងគាត់ចងចាំថ្ងៃខែខ្មែរយើងប៉ុន្តែគាត់មិនបានប្រាប់ទេ

កៈ អូ៎!!បាទអ៊ុំបាទ?

ខៈ នៅថ្ងៃខែបារាំងនឹងគាត់អត់ចងចាំទេ ចា៎!!ពីដើមនឹងចឹងទៅណាស់

កៈ បាទអ៊ុំបាទត្រូវហើយអ៊ុំ?

ខៈ ចា៎!!នឹងហើយ

កៈ ចុះឆ្នាំច័ន្ទគតិអ៊ុំមានចងចាំឆ្នាំអីគេទេ លក្ខណះឆ្នាំជូត ឆ្លូវ ខាល ថោះនឹង?

ខៈ បើឆ្នាំនឹងអ៊ុំឆ្នាំមមែនឹងហាស

កៈ ចឹងអ៊ុំឆ្នាំមមែណអ៊ុំ?

ខៈ ចា៎!!ឆ្នាំមមែនឹងហាស

កៈ ចុះអ៊ុំកើតនៅណាដែរអ៊ុំ?

ខៈ និយាយទៅអ៊ុំកើតនៅកម្ពុជាក្រោមហើយ
ដល់ពេលទៅពុកម៉ែរបស់អ៊ុំមកនៅភ្នំពេញនឹងដល់ពេលដែររួចទៅអ៊ុំគាត់កើតនៅកម្ពុជា
ក្រោមប៉ុន្តែគាត់មកនៅភ្នំពេញ
ហើយរួចទៅចេញពីភ្នំពេញនឹងហើយក៏ទៅកម្ពុជាក្រោមវិញហាស

កៈ បាទអ៊ុំប៉ុន្តែនៅភូមិអីឃុំអីដែរស្រុកអ៊ុំកើតនឹងហាស?

ខៈ ភូមិកើតនឹងនៅស្រុកកំណើតណុងគេហៅជាខ្មែរព្រះត្រពាំង

កៈ ភូមិព្រះត្រពាំងហោសអ៊ុំ?

ខៈ នឹងហើយអ៊ុំនៅណុងគេហៅព្រះត្រពាំងនឹង

កៈ ប៉ុន្តែនៅឃុំអីគេដែរអ៊ុំ?

ខ៖ ដល់ពេលឥឡូវនឹងគេប្រែប្រួលអស់ហើយនឹងអ៊ុំអត់ចងចាំកូន

ក៖ ប៉ុន្តែនៅស្រុកអីគេដែរអ៊ុំ?

ខ៖ ស្រុកណុងគេហៅស្រុកកំពង់សាន្ត

ក៖ នៅស្រុកកំពង់សាន្តណាអ៊ុំ?

ខ៖ ចា៎!!នៅកំពង់សាន្ត នៅវត្តកំពង់សាន្តមានវត្តមានអីចឹងទៅណាស់

ក៖ នៅកម្ពុជាក្រោមនឹង

ខ៖ ចា៎!!នឹងហើយ

ក៖ ចុះអ៊ុំមានបងប្អូនចំនួនប៉ុន្មាននាក់ដែរអ៊ុំ?

ខ៖ បងប្អូនរបស់អ៊ុំនឹងមាន7នាក់ហោស

ក៖ ប៉ុន្តែអ៊ុំជាកូនទីប៉ុន្មានដែរទៅអ៊ុំ?

ខ៖ អ៊ុំជាកូនទី4នឹងហោស

ក៖ ចុះមានស្រីប៉ុន្មាននាក់ នឹងប្រុសប៉ុន្មាននាក់ដែរទៅអ៊ុំ?

ខ៖ អ៊ុំមានបងប្អូនស្រី5នាក់នឹងប្រុស2នាក់នឹងហាស

ក៖ អូ៎!!!បាទអ៊ុំបាទ?

ខ៖ ប្រុសមានតែពីរគ្រាប់នឹងទេ

ក៖ ចុះអ៊ុំអាចប្រាប់ឈ្មោះពួកគាត់បានទេអ៊ុំ?

ខ៖ ឈ្មោះគាត់បងទីមួយនឹងឈ្មោះខ្មី

ក៖ ឈ្មោះខ្មី?

ខ៖ បងទីពីនឹងឈ្មោះផាតចឹង

ក៖ ចុះបងទី3ហោសអ៊ុំ?

ខ៖ បងទី3នឹងឈ្មោះឡាំង តែស្លាប់អស់ហើយនឹងនៅតែបងមួយនឹង

កៈ អូ៎!!ប៉ុន្តែប្អូនវិញអ៊ុំ?
ខៈ ប្អូនមួយនឹងមួយឈ្មោះណារី នឹងមួយទៀតឈ្មោះណារិន

កៈ ចឹងពៅគេមានឈ្មោះណារិនហោសអ៊ុំ?

ខៈ ចា៎!!នឹងហើយមានឈ្មោះស្រៀង

កៈ ឈ្មោះ ស្រៀង ចុះមានស្លាប់ប៉ុន្មាននាក់ នឹងរស់ប៉ុន្មាននាក់ដែរអ៊ុំ?

ខៈ ស្លាប់អស់ពីរនាក់ចឹងហើយ ស្លាប់អស់ពីរនាក់នៅតែ5នាក់នឹង

កៈ ចឹងស្លាប់អស់ពីរនាក់ នៅសល់តែ5នាក់ទេណអ៊ុំ?

ខៈ ចា៎ៗៗ!!នឹងហើយ

កៈ ចុះអ៊ុំមានចងចាំថាកាលពីអ៊ុំនៅក្មេងៗៗនឹងអ៊ុំមានធ្លាប់បានធ្វើអីគេជាមួយគាត់ដែរទេអ៊ុំ ដូចជាលេងឡឹកបាយឡ លេងបិទពួនអីចឹងហាស?

ខៈ កាលនៅក្មេងអ៊ុំអត់សូវបានលេងទេគ្រួសាររបស់អ៊ុំនឹងទីទាល់ក្រណាស់

កៈ ចឹងហោសអ៊ុំ?

ខៈ ចា៎!!អ៊ុំទៅស៊ីឈ្នួលគេដើម្បីអ៊ុំអាចយកកំរៃនឹងបានមកជួយពុកម៉ែហាស

កៈ អូ៎!!ចឹងហោសអ៊ុំ?

ខៈ ចា៎!!នឹងហើយ

កៈ ចឹងអ៊ុំអត់ដែរបានធ្វើអីរីលេងអីជាមួយបងប្អូនរបស់អ៊ុំទេ?

ខៈ អត់បានធ្វើអីទេបងប្អូនរបស់អ៊ុំនឹងបើបងធំនឹងធំឡើងគាត់បួស ហើយបើអ៊ុំនឹងដើរទៅស៊ីឈ្នួលគេនឹង

កៈ អូ៎!!ប៉ុន្តែអ៊ុំមានធ្លាប់គិតថាកាលពីនៅតូចៗៗនឹងអ៊ុំធ្លាប់លេងអីជាមួយពួកគាត់ដែរហាស ដូចជាលេងបិទពួននឹងលេងអីចឹងហាស មានទេអ៊ុំ?

ខ៖ អ៊ុំអត់មានបានពេលមកលេងទេនិយាយត្រង់តែម្ដងនឹងអូន
បងប្អូនរបស់អ៊ុំនឹងតូចៗប៉ុនៗៗនេះនឹង
គឺដើរអស់ហើយខ្លះតៅចាំចាបម៉ែឪទៅធ្វើស្រែចឹងទៅ

ក៖ ប៉ុន្តែអ៊ុំធ្លាប់មានអនុស្សាវរីយ៍អីទៅស្រែជាមួយពួកគាត់ដែរតើហីអ៊ុំ
ទៅមើលស្រែទៅធ្វើស្រែ?

ខ៖ ស្ទូង ទៅស្រែទៅអីនឹងខ្ញុំទៅភ្ជួររាស់អី ដល់ពេលដែរធំតិចនឹងអ៊ុំទៅឃ្វាលក្របីអីនឹង
វាអត់បាននៅជាមួយគ្នាបែករលែកគ្នាម្នាក់ទៅនេះម្នាក់ទៅនោះ
ព្រឹកឡើងនឹងពុកម៉ែគាត់ចែកហើយចេះតែដាក់អោយទៅ ណាស់អ៊ុំទៅឃ្វាលក្របី
អាបងទៅចំការចឹងទៅ

ក៖ អូ៎!!ចែកគ្នាធ្វើណាអ៊ុំ?

ខ៖ ចា៎!!នឹងហើយជំនាន់ណុងគេធ្វើស្រែចំការនឹងកូន

ក៖ អូ៎!!បាទអ៊ុំបាទ?

ខ៖ ចា៎!!ចឹងឯង

ក៖ ចុះបងប្អូនរបស់អ៊ុំគាត់ឥឡូវនឹងគាត់នៅណាដែរអ៊ុំ?

ខ៖ គាត់នៅកម្ពុជាទាំងអស់នឹងហាស

ក៖ ចឹងនៅតែអ៊ុំទេដែរនៅនឹង?

ខ៖ ចា៎!!នៅតែអ៊ុំទេដែរនៅនឹងហាសយូរដែរហើយ
អស់30ឆ្នាំហើយនឹង30ឆ្នាំជាងហើយនឹងហាស

ក៖ និយាយចឹងអ៊ុំមកនៅនឹង30ឆ្នាំជាងហើយ?

ខ៖ អស់ជាង30ឆ្នាំហើយនឹងហាស

ក៖ យូរដែរចឹង?

ខ៖ យូរដែរហើយនឹងហាស

ក៖ ចុះពួកគាត់ធ្វើអីគេដែរនៅណុងនៅកម្ពុជាក្រោមនឹងហាស?

ខ៖ មកនៅកម្ពុជាក្រោមកូនរបស់អ៊ុំនឹងមកនៅទាំងអស់នឹងហាស

ក៖ ប៉ុន្តែបងប្អូនរបស់អ៊ុំហាសគាត់ធ្វើអីគេដែរ?

ខ៖ អ៎ូ!!ធ្វើស្រែចំការនឹង

ក៖ បាទអ៊ុំបាទ?

ខ៖ អត់មានធ្វើអីក្រៅពីស្រែចំការទេនឹង

ក៖ ចុះឪពុករបស់អ៊ុំគាត់ឈ្មោះអីគេដែរអ៊ុំ?

ខ៖ គាត់មានឈ្មោះតាភេន

ក៖ ដូចជាគាត់កើតនៅណាដែរអ៊ុំ?

ខ៖ គាត់កើតនៅណោះហាស ដល់ពេលហើយគាត់មកនៅនឹងគាត់វិលមកនឹងហាស

ក៖ ប៉ុន្តែគាត់កើតនៅកម្ពុជាក្រោមដែរ?

ខ៖ ចា៎!!នឹងហើយ

ក៖ ចុះម្តាយរបស់អ៊ុំវិញគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខ៖ ម្តាយគាត់មានឈ្មោះគីម សម័យ

ក៖ ប៉ុន្តែគាត់នៅកម្ពុជាក្រោមនឹងដែរ?

ខ៖ គាត់នៅកម្ពុជាក្រោមនឹងដែរដូចថា
កាលពីមុនអីកាត់មកនៅបងប្អូននៅបាត់ដំបងអីគាត់នៅរកស៊ី
ជាមួយអីចឹងដល់ពេលរួចទៅគាត់ចុះទៅក្រោមវិញទៅ

ក៖ និយាយរួមនឹងបងប្អូនរបស់អ៊ុំនឹងសុទ្ធតែនៅកម្ពុជាក្រោមនឹងទាំងអស់នឹងមែនអ៊ុំ?

ខ៖ ចា៎ៗ!!នឹងហើយ

ក៖ បាទអ៊ុំចុះឪពុកម្តាយរបស់អ៊ុំគាត់នៅរស់ទាំងអស់តើមែនទេអ៊ុំ?

ខ៖ ឪពុកនឹងស្លាប់យូរហើយកូនអើយ

កៈ  អូ!!គាត់ស្លាប់អស់ហើយហោសអ៊ុំ?

ខៈ  ចាំ!!នឹងហើយ

កៈ
ប៉ុន្តែឪពុកកាលពីគាត់នៅរស់នឹងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមក្រុមគ្រួសារនឹងចិញ្ចឹមជីវិតដែរអ៊ុំ?

ខៈ  គាត់ធ្វើស្រែចំការហើយធ្វើៗៗហើយរួចនឹងគាត់ជាងបោះតុ ទូអីចឹងហាសណាស់

កៈ  បាទអ៊ុំបាទ?

ខៈ  ជាជាងតុ ទូអីចឹងគាត់ដើរទិញឈើលក់ឈើអីចឹងទៅកូន

កៈ  បាទប៉ុន្តែគាត់ស្លូតរឺមួយក៏គាត់កាចដែរអ៊ុំ?

ខៈ  គាត់ធម្មតានឹងកូនអើយ គាត់មិនស្លូត ហើយក៏មិនកាចពេកដែរនឹង

កៈ  បាទអ៊ុំបាទ?

ខៈ  គាត់ធម្មតានឹងហាស

កៈ  ចុះដូចជាម្តាយរបស់អ៊ុំនឹងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ?

ខៈ  ម្តាយគាត់ធ្វើចំការនឹងកូន

កៈ  គាត់ធ្វើចំការហោសអ៊ុំ?

ខៈ  មានអីក្រៅពីធ្វើចំការនឹងកូនឪពុកដាំចំការធ្វើស្រែប៉ុន្តែស្រែនឹង

កៈ  បាទអ៊ុំបាទ?

ខៈ  ស្រែនឹងបន្តិចបន្តួច នឹងចំការនឹងបន្តិចបន្តួចដែរនឹង

កៈ  បាទអ៊ុំបាទ ចុះម្តាយរបស់អ៊ុំគាត់កាចរឺមួយក៏ស្លូតដែរអ៊ុំ?

ខៈ  គាត់មិនកោងកាចអីជាមួយនរណាគេទេក្មួយ

កៈ  អូ!!គាត់ស្លូតដែរចឹងហោសអ៊ុំ?

ខ៖  ចា៎!!អ្នកស្រុកភូមិនឹងរាប់អានគ្នាស្រលាញ់គ្នាណាស់

ក៖  បាទអ៊ុំបាទ?

ខ៖  ដូចថាប្រហុក អំបិល អីចឹងយើងខ្វះចឹងសុំគ្នាទៅវិញទៅមកនឹង

ក៖  លក្ខណះមិត្តជិតខាងនឹងហោសអ៊ុំ?

ខ៖  លក្ខណះម៉ាសំលនឹងហាសយើងធ្លាប់សុំគេ
ហើយគេក៏ធ្លាប់សុំយើងដែរលក្ខណះមួយសំលទៅ នឹងមួយសំលមកចឹង

ក៖  បាទអ៊ុំបាទ?

ខ៖  បើថាស្រូវអង្ករទេខ្វះអីអាចខ្ចីគ្នាបាន

ក៖  បាទអ៊ុំបាទ?

ខ៖  កាលជំនាន់ណុងហាស

ក៖  ចុះអ៊ុំមានចងចាំថាធ្លាប់មានអនុស្សាវរីយ៍អីជាមួយគ្នាធ្លាប់បានធ្វើអីជាមួយគ្នាដែរទេអ៊ុំ?

ខ៖  អ៊ុំមានអីក្រៅពីទៅធ្វើស្រែចំការឪពុកគាត់ធ្វើភ្លួរ
អ៊ុំទៅឃ្វាលក្របីជញ្ជូនក្របីអីជាមួយគាត់ចឹងហាស

ក៖  បាទអ៊ុំបាទ?

ខ៖  ជូនទៅភ្លួរអីចឹង

ក៖  ចុះទៅស្រែថ្លាប់មានអនុស្សាវរីយ៍អីនៅស្រែធ្លាប់ធ្វើស្រែធ្វើអីចឹងហាស?

ខ៖  ទៅស្រែធ្លាប់ធ្វើស្រែធ្វើអីចឹង ដកស្ទូងអីចឹង
កញ្ចប់បាយអីចឹងហាសនៅស្រែហាសណាស់

ក៖  បាទអ៊ុំបាទ?

ខ៖  ចា៎!!ចឹង

ក៖  ចុះឪពុករបស់អ៊ុំគាត់ធ្លាប់ប្រាប់ពីប្រវត្តិរបស់គាត់ទៅអ៊ុំទេ?

ខ៖  គាត់នឹងគាត់មិនសូវដែរប្រាប់អីទេ គាត់អត់ដែរសូវប្រាប់អីទេកូន

កៈ ចុះម្តាយរបស់អ៊ុំគាត់ធ្លាប់ប្រាប់ពីប្រវត្តិកាលពីក្មេងទៅអ៊ុំដែរទេ?

ខៈ អត់សូវបានប្រាប់ទេកូនអើយ

កៈ បាទអ៊ុំបាទ?

ខៈ ដូចដែរអ្វីដែរអ៊ុំប្រាប់ចឹងកូនអើយអ៊ុំអាយុ12ឆ្នាំអ៊ុំស៊ីឈ្នួលគេហើយនឹងហាស ហើយដល់ពេល12ឆ្នាំ នឹងឡើងទៅស៊ីឈ្នួលនៅព្រៃអង្គរហោស

កៈ អូ!!ចឹង?

ខៈ ចា៎!!ហើយពេលដែរបាន1-2ឆ្នាំវិលមកស្រុកនឹងម៉ែអោយទៅស៊ីឈ្នួលគេនៅវាលស្រែហោស នៅចុះទៅស្រុកស្រែទៀតនឹង ស្រុកស្រែដល់ពេលដែររួចទៅ ដល់ពេលដែរធំតិចនឹងទៅស៊ីឈ្នួលគេ នៅណោះទៀតនឹង

កៈ អូ!!ចឹងអ៊ុំទៅធ្វើការស៊ីឈ្នួលគេរហូតណាអ៊ុំ?

ខៈ ចា៎!!អ៊ុំម៉ែឪខ្សត់ខ្សោយណាស់

កៈ អូ!!ចឹង?

ខៈ ដល់ពេលចឹងអ៊ុំមិនសូវជាមានអនុស្សាវរីយ៍អីជាមួយគ្នាច្រើនទេនឹង

កៈ អូ!!បាទអ៊ុំ?

ខៈ អ៊ុំដើរស៊ីឈ្នួលគេ

កៈ ចុះយាយតាខាងម្តាយអ៊ុំមានស្គាល់ឈ្មោះគាត់ដែរទេ?

ខៈ យាយតាខាងម្តាយនឹងគាត់

កៈ គាត់មានឈ្មោះអីគេអ៊ុំមានស្គាល់ដែរទេ?

ខៈ គាត់តាឆាយចឹងហើយចឹងហើយ

កៈ ចុះយាយវិញអ៊ុំ?

ខៈ ឈ្មោះយាយឈី

កៈ នឹងខាងម្ដាយណាអ៊ុំណា?

ខៈ ចាំ!!នឹងហើយ

កៈ ចុះខាងឪពុកអ៊ុំមានស្គាល់ឈ្មោះគាត់ដែរទេ?

ខៈ ឈ្មោះតាព្រាម នឹងយាយភឿង

កៈ ប៉ុន្តែពួកគាត់កើតនៅណាដែរអ៊ុំ នៅកម្ពុជាក្រោមទាំងអស់រឺមួយយ៉ាងម៉េចដែរអ៊ុំ?

ខៈ ចាំ!!គាត់នៅកម្ពុជាក្រោមដែរនឹងហាស

កៈ អូ៎!!បាទអ៊ុំបាទ?

ខៈ ចាំ!!នឹងហើយ

កៈ ចុះអ៊ុំមានសាច់ញ្ញាតិណារឺមួយក៏បងប្អូនដែរទៅរស់នៅក្រៅប្រទេសទេអ៊ុំ?

ខៈ អត់ទេកូនអើយ

កៈ ប៉ុន្តែមាននៅព្រៃងអង្គរហើអ៊ុំនៅកម្ពុជាក្រោមហើអ៊ុំ?

ខៈ មាននៅកម្ពុជាក្រោមនឹង

កៈ ចឹងនៅថៃ នៅវៀតណាមអីអត់មានទេណអ៊ុំ មានតែនៅកម្ពុជាក្រោមនឹងទេហោសអ៊ុំ?

ខៈ ចាំ!!នៅកម្ពុជាក្រោមនឹង

កៈ បាទអ៊ុំបាទ?

ខៈ អត់មាននៅថៃទេ

កៈ ចុះស្វាមីរបស់អ៊ុំនឹងមានឈ្មោះអីគេដែរអ៊ុំ?

ខៈ គាត់មានឈ្មោះភឿន គីម ហីប

កៈ ប៉ុន្តែគាត់នៅរស់សព្វថ្ងៃនឹងតើហើអ៊ុំ?

ខៈ គាត់ស្លាប់បាត់ហើយនឹង

កៈ អូ៎!!បាទអ៊ុំបាទ?

ខ៖ គាត់ស្លាប់4-5ឆ្នាំទាំងនៅឆ្នាំនឹងហើយ

ក៖ ចុះអ៊ុំមានចងចាំថាអ៊ុំរៀបអាពាហ៍ពិពាហ៍នៅថ្ងៃខែឆ្នាំណាដែរទេអ៊ុំ?

ខ៖ អ៊ុំអត់ចងចាំទេ

ក៖ អូ៎!!បាទអ៊ុំ ចុះនៅពេលដែរអ៊ុំរៀបអាពាហ៍ពិពាហ៍នឹងគិតថាអ៊ុំជាអ្នករៀបចំដោយចិត្តឯងរឺមួយក៏ឪពុកម្ដាយជាអ្នកចំអោយដែរ?

ខ៖ ទេឪពុកម្ដាយទេកូនអើយកាលពីជំនាន់ណុងមិនសូវចេះរៀបចំដោយចិត្តឯងទេនឹង

ក៖ បាទអ៊ុំបាទ?

ខ៖ ឪពុកម្ដាយទេនឹង

ក៖ ចុះមានជាជំនូនទេប្ដីរបស់អ៊ុំចូលស្ដីណ្ដឹងអ៊ុំចឹងមានជាជំនូនទេ?

ខ៖ ជំនូនកាលពីជំនាន់ណុងក៏អត់មានច្រើនដែរកូន

ក៖ បាទចឹងអ៊ុំ?

ខ៖ តិចតួចគ្រាន់តែថាបានមួយរៀបចំ

ក៖ បានមួយរៀបចំហើយណអ៊ុំ?

ខ៖ ចា៎!!បានរៀបចំហើយនឹងហាស
យើងខ្វះគ្រាន់អីយើងនឹងកូនស្រីនឹងជួយចេញខ្លះចឹងទៅណាស់កូន

ក៖ អូ៎!!ចឹងហោសអ៊ុំ?

ខ៖ ចា៎ៗ!!នឹងចឹង

ក៖ ចុះអ៊ុំដូចជាអ៊ុំធ្លាប់បានចូលរៀនភាសាខ្មែរបានល្អប៉ុណ្ណាដែរអ៊ុំ?

ខ៖ អ៊ុំអត់បានរៀនទេកូនអើយអ៊ុំរៀនបានតារយះបងគាត់បួស

ក៖ អូ៎!!ចឹងហោសអ៊ុំ?

ខ៖ បងគាត់បួសទៅគាត់ចេះអក្សរខ្មែរនឹងហាស
ហើយគាត់បានបង្រៀននៅនឹងផ្ទះនឹងហាស

កៈ បាទអ៊ុំបាទ?

ខៈ ហើយបង្រៀនតាំងពីតូចមកនឹង ហើយដល់ពេលដែរធំឡើងនឹងទៅស៊ីឈ្នួលគេចឹងទៅដល់ចឹងភ្លេចអស់ហើយអត់ចងចាំទេកូនអើយ

កៈ អ៊ូ!!ចឹងហោសអ៊ុំ?

ខៈ ចា៎!!នឹងហើយចឹង

កៈ បាទអ៊ុំមានចេះភាសាអីក្រៅពីភាសាខ្មែរដែរទេអ៊ុំ?

ខៈ អ៊ុំនៅកម្ពុជាក្រោមនឹងនៅជាមួយនឹងវៀតណាមនឹងហាស

កៈ ចឹងអ៊ុំចេះវៀតណាមដែរអ៊ុំ?

ខៈ អ៊ុំចេះវៀតណាមនឹងហាស

កៈ អ៊ូ!!ល្អដែរតើអ៊ុំ?

ខៈ ចា៎!!ចេះភាសាវៀតណាមនឹងហាស

កៈ ចុះដូចជាអ៊ុំមានមិត្តភក្តិណាដែរស្និទ្ធិស្នាលធំធាត់មកជាមួយគ្នាដែរទេអ៊ុំ?

ខៈ មិត្តភក្តិស្និទ្ធិស្នាលឥឡូវនឹងគេមានគ្រួសារគេបែកគេចទៅណាអស់ហើយនឹង

កៈ ប៉ុន្តែពួកគាត់មានឈ្មោះអីគេខ្លះដែរអ៊ុំមានចងចាំដែរទេ?

ខៈ

ចា៎!!មិត្តភក្តិស្និទ្ធិស្នាលនឹងស្និទ្ធិស្នាលជាគេនឹងឥឡូវនឹងគាត់ចាស់គាត់ឈឺគាត់ដើរលែងរួចហើយនឹងហាសចឹង

កៈ បាទប៉ុន្តែគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខៈ ឈ្មោះអីគេទេឈ្មោះពិបាកហៅដែរនឹងឈ្មោះណោចឹងហាស

កៈ ឈ្មោះណោហោសអ៊ុំ?

ខៈ ចា៎!!នឹងហើយ

ក៖  ប៉ុន្តែអ៊ុំធ្លាប់មានចងចាំអនុស្សាវរីយ៍អីកាលអ៊ុំនៅក្មេងៗជាមួយគាត់ដែរទេធ្លាប់ធ្វើអីជាមួយគាត់ដែរចឹងហាសអ៊ុំ?

ខ៖  ខ្ញុំចងចាំទៅអត់បានដើរលេងអីទេគ្រាន់តែថាឃ្វាល

ក៖  ទៅឃ្វាលគោ ឃ្វាលក្របីណអ៊ុំ?

ខ៖  ទៅឃ្វាលគោ ឃ្វាលក្របីជាមួយគ្នានឹង

ក៖  អូ៎!!បាទអ៊ុំបាទ?

ខ៖  ថ្ងៃឡើងគេទៅជួបជុំគ្នាលេងអីនៅវាលស្រែលេងនឹងហាស

ក៖  បាទអ៊ុំបាទ?

ខ៖  មានតែចឹងនឹងហាស

ក៖  បាទអ៊ុំចឹង?

ខ៖  ចា៎!!វាចឹងនឹង

ក៖
ចុះអ៊ុំគិតថាតាំងពីក្មេងរហូតមកដល់ពេលនេះនឹងការងារអីគេខ្លះដែរអ៊ុំធ្លាប់បានធ្វើដែរអ៊ុំ?

ខ៖  អ៊ុំពីក្មេងរហូតនឹងអ៊ុំធ្វើហាត់ហាសកូនអើយ
នៅស៊ីឈ្នួលគេនឹងធ្វើការងារធ្ងន់ៗហាសណាស់

ក៖  អូ៎!!ធ្វើការងារធ្ងន់ៗហោសអ៊ុំ?

ខ៖  រែកសំណាប កាលពីជំនាន់ណុងគ្មានម៉ាស៊ីនទំនើបអីចឹងៗទេណាស់

ក៖  បាទអ៊ុំបាទ?

ខ៖  រែកសំណាប
សំណាបនឹងរែកទៅវាលស្រែទៅថ្នល់ពីថ្នល់មកផ្ទះយើងនឹងវាឆ្ងាយហាសណាស់

កៈ
ហើយដល់ពេលដែរជំនាន់ណុងក្របីគេបោលក្របីជាន់អត់មានម៉ាស៊ីនចឹងទេអត់មានទំនើបចឹងទេ

កៈ អូ៎!!ចឹងទេហោសអ៊ុំ?

ខៈ អត់មានទំនើបចឹងទេ
ចា៎!!ហើយស្រូវអីចឹងកើបដាក់ជង្រុកអីចឹងលើកទាំងតៅៗៗឡើងដាក់ជណ្ដើរ
ដាក់លើកជង្រុកអីចឹងហាសនៅនឹងគេចេះតែធ្វើចឹងទៅណាស់អូន

កៈ បាទចឹងដល់ពេលដែរឥឡូវនឹងអ៊ុំឈប់ធ្វើអីហើយណាអ៊ុំ?

ខៈ អ៊ុំទើបតែឈប់ធ្វើឆ្នាំនេះនឹងហាស
អ៊ុំទៅស៊ីឈ្នួលទៅចាក់ជើងទាននឹងអោយគេដែរនឹងហាស

កៈ បាទអ៊ុំបាទ?

ខៈ អ៊ុំទៅស៊ីឈ្នួលគេដែរនឹងហាស
ដល់ពេលដែរកូនទៅលក់អត់មាននរណាគេមើលថៅនឹង
ចឹងគេហៅអោយមកយកថៅអោយគេទៅនឹង

កៈ ចឹងប៉ុន្តែគេឈប់អោយអ៊ុំធ្វើអីហើយមែនទេអ៊ុំ?

ខៈ គេក៏ឈប់អោយធ្វើអីទៅនឹងហាស

កៈ អូ៎!!បាទអ៊ុំបាទ?

ខៈ ចា៎!!នឹងហើយ

កៈ ចុះអ៊ុំគិតថាអ៊ុំធ្លាប់ទៅធ្វើការងារនៅវាលស្រែទេអ៊ុំ?

ខៈ អ៊ុំអត់បានទៅធ្វើការងារនៅវាលស្រែទេនឹង
អ៊ុំទៅធ្វើការងារចាក់ជើងទានអោយគេថៅកែគេដីឡូនឹង ធំហាសណាស់

កៈ បាទអ៊ុំបាទ?

ខ៖
អ៊ុំទៅចាក់តាយាយអ៊ុំចាក់រហូតនឹងតាគាត់ស្លាប់បាត់ទៅអ៊ុំទៅធ្វើនឹងទៀតនឹងពីព្រោះកូនចៅនឹងវា ខ្សត់ខ្សោយនឹងដែរហាស គ្មាមិនសូវមានដែរនឹង គាត់រត់ម៉ូតូឌុបនឹងរត់តុតុនឹងហាស

ក៖ បាទអ៊ុំបាទនឹងប៉ុន្តែអ៊ុំទៅចាក់ជើងទាននឹងអ៊ុំទៅចាក់នៅណាអ៊ុំ?

ខ៖ ទៅចាក់ជើងទាននៅបឹងតាម៉ាតហោសថៅគេមាន

ក៖ នៅភ្នំពេញនឹងតើហីអ៊ុំ?

ខ៖ នៅភ្នំពេញនឹងតើ នៅបឹងតាម៉ាតយើងនឹងហួសស្ពានដែកនឹង

ក៖ អូ៎!!បាទអ៊ុំបាទ?

ខ៖ ចាក់មិនទាន់បានឈប់សឹងមិនទាន់បានមួយឆ្នាំផងនឹងបានតែ5-6ខែនឹង

ក៖ បាទអ៊ុំបាទ ចុះអ៊ុំធ្លាប់បើកអាជីវកម្មអីទេអ៊ុំ ដូចថាលក់ដូរអីចឹងហាស?

ខ៖ ពីដើមនឹងអ៊ុំលក់បន្លែអ៊ុំលក់បន្លែនៅផ្សារដើមថ្កូវនេះនឹងហាស

ក៖ អូ៎!!បាទអ៊ុំបាទ?

ខ៖
ហើយដល់ពេលរួចទៅអ៊ុំផ្លាស់ផ្ទះពីនេះទៅអ៊ុំទៅនៅចំការដូងនឹងអ៊ុំឈប់លក់បន្លែទៅនឹងហាស
អ៊ុំឈប់លក់បន្លែនឹងអ៊ុំទៅនៅនឹងហើយតាយាយនឹងប្តីរបស់អ៊ុំនឹងឈប់រត់ម៉ូតូឌុបនឹង

ក៖ បាទអ៊ុំបាទ?

ខ៖ ពីរនាក់នឹងទៅចាក់ជើងទាន់នឹងអោយគេគ្រាន់តែបានហូបចុងរាល់ថ្ងៃនឹងចិញ្ចឹមនេះចឹង

ក៖ ចិញ្ចឹមជីវិតណាអ៊ុំ?

ខ៖ ចា៎!!ចិញ្ចឹមតាយាយនឹងហាស ចាចិញ្ចឹមតាចិញ្ចឹមយាយនឹង
ហើយដល់ពេលដែរគាត់ស្លាប់ចឹងទៅអ៊ុំនៅធ្វើ

កះ  អ៊ុំនៅធ្វើម្នាក់ឯងចឹងទៅ?

ខះ  ធ្វើម្នាក់ឯងចឹងទៅណាស់

កះ  ចុះអ៊ុំធ្លាប់ចិញ្ចឹមសត្វទេ ធ្លាប់ចិញ្ចឹមគោ ចិញ្ចឹមក្របី ចិញ្ចឹមទាអីចឹងហាស?

ខះ  អត់ទេអូនអត់បានចិញ្ចឹមទេ

កះ  ចឹងអត់ដែរចិញ្ចឹមទេណាអ៊ុំ?

ខះ  ចាំៗ!!កាលពីកូននៅក្មេងនឹងមានដែរបានចិញ្ចឹមជ្រូកដែរ
ចិញ្ចឹមលក់ជ្រូកបានពីរបីដងអីអ៊ុំលែង ចិញ្ចឹមហាសអ៊ុំខ្លាចបាប

កះ  អូ៎!!អ៊ុំខ្លាចបាបហោសអ៊ុំ?

ខះ  ចាំ!!នឹងហើយខ្លាចបាបអ៊ុំក៏ឈប់ចិញ្ចឹមទៅនឹង

កះ  បាទអ៊ុំ ចុះអ៊ុំគិតថាជីវិតរបស់អ៊ុំមានការផ្លាស់ប្តូរអីគេខ្លះដែរអ៊ុំ
តាំងពីក្មេងរហូតមកដល់ពេលនេះហាសអ៊ុំ?

ខះ  ផ្លាស់ប្តូរនឹងក៏ដូចជាមិនផ្លាស់ដែរពីព្រោះអីជីវភាពនឹងវាខ្សត់ខ្សោយ
អោយបានធូរធានឹងមែនទែនអី
អីគ្រាន់តែថាអើរបានតែដោះស្រាយជាងមុនតិចចឹងវាល្អដែរនឹងកូន

កះ  បាទអ៊ុំបាទ?

ខះ  ចាំៗ!!នឹងហើយ

កះ  ចុះអ៊ុំចូលចិត្តពិសារម្ហូបអីគេដែរអ៊ុំ?

ខះ  អ៊ុំមានថាម្ហូបអីទេយើងក្រយើងអត់ចឹងបានថ្ងៃណាបានម្ហូបឆ្ងាញ់ៗអត់ក៏អត់ទៅនឹង
ចឹងកូនវាចៀនត្រីងៀតចឹងជូនណាវាចៀនពងទាអីចឹងហូបហើយនឹងហាស

កះ  ប៉ុន្តែម្ហូបដែរអ៊ុំចូលចិត្តតែម្តងនឹងម្ហូបអីគេដែរអ៊ុំ?

ខះ  ម្ហូបដែរចូលចិត្តនឹងអ៊ុំពីដើមនឹងច្រើនតែ ប្រហុកវេចបាយកញ្ចប់ទៅស្រែអីចឹងហាស

កះ  បាទចឹងអ៊ុំ?

ខ៖ ហើយនៅជំនាន់ណុងវានៅតែចូលចិត្តហូបប្រហុកវាឆ្ងាញ់នឹង

ក៖ អូ!!ចឹងមានន័យថាអ៊ុំចូលចិត្តហូបប្រហុកណាអ៊ុំ?

ខ៖ នឹងហើយវាឆ្ងាញ់អាប្រហុកនឹងហើយនឹង

ក៖ ចុះអ៊ុំល្បែងប្រជាប្រិយ៍អីគេដែរអ៊ុំចូលចិត្តលេងតាំងពីក្មេងហាស ដូចលក្ខណះថា?

ខ៖ អ៊ុំចូលចិត្តលេងអាបិទពួននឹងហើយអាអោបអន្ទាក់នឹង

ក៖ ប៉ុន្តែល្បែងប្រជាប្រិយ៍ដូចជាលាក់កន្សែង ចោលឈូង បោះអង្គុញ
ទាញព្រាតអីចឹងហាសអ៊ុំ?

ខ៖ ចា៎ៗៗ!!នឹង

ក៖ អ៊ុំចូលចិត្តលេងដែរទេ?

ខ៖ ចា៎!!ចូលចិត្តលេងអានឹង

ក៖ អូ!!បាទអ៊ុំ ប៉ុន្តែអ៊ុំចេះច្រៀងទេអ៊ុំ?

ខ៖ ចា៎!!អត់ចេះច្រៀងទេនឹង

ក៖ អូ!!បាទប៉ុន្តែអ៊ុំចូលចិត្តស្តាប់បទចំរៀងដែរទេ?

ខ៖ ចា៎!!បើអ៊ុំចូលចិត្តស្តាប់បទចំរៀងនឹងចូលចិត្តបទពីដើមៗដែរនឹងហាស

ក៖ អូ!!បទពីដើមណាអ៊ុំ?

ខ៖ ចា៎!!សម័យឥឡូវនឹងអ៊ុំអត់ចេះស្តាប់ទេ

ក៖ អូ!!បាទអ៊ុំបាទ?

ខ៖ ចូលចិត្តតែបទពីដើមៗនឹងហាសបើសាម៉ុតអីច្រៀងចឹងអ៊ុំចូលចិត្តហាស

ក៖ អូ!!បាទអ៊ុំបាទ?

ខ៖ កូនចៅគេនឹងចាក់អោយស្តាប់

ក៖ ចុះមាននរណាគេមួយនៅក្នុងក្រុមគ្រួសាររបស់អ៊ុំចេះលេងឧបករណ៍ភ្លេងដែរទេអ៊ុំ?

ខ៖ ទេអត់មានទេកូនអើយអ៊ុំអត់ដឹងដែរទេអ៊ុំនឹងហាស តាមខ្សែរយះអីនឹងអត់ដឹងទេ

ក៖ អូ៎!!បាទអ៊ុំបាទ?

ខ៖ នឹងហើយចឹង

ក៖
ចុះអ៊ុំគិតថាផ្ទះរបស់អ៊ុំនឹងមានលក្ខណះបែបណាដែរតាំងពីក្មេងរហូតមកដល់ពេលនេះហាសអ៊ុំ?

ខ៖ មិនមែនថាវាអត់លុយទេ អ៊ុំជំពាក់លុយនឹងអ៊ុំរើរហូតនឹងអូន
អ៊ុំតាំងពីដើមនឹងអ៊ុំនៅក្បាលមាន់ចៃ

ក៖ បាទអ៊ុំបាទ?

ខ៖
ដល់ពេលដែរអ៊ុំជំពាក់លុយគេអ៊ុំលក់ពីក្បាលមាន់ចៃមកអ៊ុំមកនៅនាគមាសបន្ទាប់មកអ៊ុំមកនៅអេអិនសិតមកដល់ពេលដែរជំពាក់បំណុលគេលក់មកសងបំណុលគេនឹង
ហើយមកទិញនៅមាត់បឹងហើយអ៊ុំមកនៅចំការដូង

ក៖ នៅចំការដូងហោសអ៊ុំ?

ខ៖ ចា៎!!លក់រហូតនឹងលក់យកលុយមកសងបំណុលគេនឹងហាស

ក៖ ប៉ុន្តែផ្ទះរបស់អ៊ុំនឹងមានលក្ខណះជាផ្ទះឈើរឺមួយក៏ផ្ទះថ្មដែរអ៊ុំ?

ខ៖ អ៊ុំមានផ្ទះឈើស័ង្កសីទេនឹង

ក៖ ចឹងហោសអ៊ុំ?

ខ៖ ក្តៅណាស់ខែប្រាំងក្តៅណាស់

ក៖ ប៉ុន្តែនរណាគេជាអ្នកសាងសងដែរអ៊ុំជាអ្នកសាងសងខ្លួនឯងរឺយ៉ាងម៉េចដែរ?

ខ៖ អ៊ុំសាងសងអ៊ុំលក់ដីទៅអ៊ុំបានទៅទិញដីនឹងបានក្បាល12នឹងបណ្តោយ20
រួចទៅអ៊ុំជំពាក់បំណុលគេទៅអ៊ុំ អ៊ុំជំពាក់បំណុលធានាគារសេងមិនរួចចឹងទៅ

ក៖ ចឹងហោសអ៊ុំ?

ខ៖ អ៊ុំខ្លាចធនាគារគេមករើសអូសយកផ្ទះ

ក៖ គេរើសអូសយកផ្ទះនឹងហោស?

ខ៖ យកផ្ទះដីអីចឹងបានពុះលក់អស់5ម៉ែត្របង់ផ្តាច់អោយគេចឹងទៅ
បានលុយមកធ្វើផ្ទះពីមុននឹងអ៊ុំផ្ទះ ខ្ទមនឹងហាស

ក៖ អូ៎!!បាទអ៊ុំបាទ?

ខ៖ ឥឡូវនឹងអ៊ុំបានសាងសងជាស័ង្កសីនៅគ្រាន់ដែរផ្ទះឈើផ្ទះស័ង្កសីហាសណាស់

ក៖ បាទអ៊ុំបាទចឹងហោស?

ខ៖ ចា៎!!នឹងចឹង

ក៖ ចុះអ៊ុំគិតថាជំនាញអីគេដែរអ៊ុំចេះស្ទាត់ជំនាញដែរអ៊ុំ?

ខ៖ អ៊ុំមានជំនាញអីក្រៅពីលក់ដូរទេកូន

ក៖ អូ៎!!ចឹងហោសអ៊ុំ?

ខ៖ ពីដើមនឹងអ៊ុំលក់បន្លែ អ៊ុំទៅទិញនៅផ្សារដើមគរមកលក់នៅផ្សារដើមថ្កូវនឹងហាស

ក៖ បាទអ៊ុំបាទចឹង?

ខ៖ ជំនាញរបស់អ៊ុំនឹងបានតែប៉ុណ្ណឹង គ្មានក្រៅអីពីលក់បន្លែទេនឹង

ក៖ បាទចុះអ៊ុំធ្លាប់គិតថាម្តាយឪពុករបស់អ៊ុំនឹងធ្លាប់បានបង្រៀនពីជំនាញអីទៅអ៊ុំដែរទេ?

ខ៖ កូនអ្នកស្រែមានបានបង្រៀនអីផងនឹងកូនអើយ
ដល់ពេលដែរធំឡើងនឹងដឹងតែធ្វើស្រែនឹង
ហើយបានបន្លែអីនឹងបានដំណាំទៅលក់នៅផ្សារនឹងហាស
ពេលដែរធំឡើងនឹងអ៊ុំចេះលក់ដូរតែម្តងនឹងហាស

ក៖ បាទអ៊ុំបាទ?

ខ៖ ចា៎!!អ៊ុំចេះលក់ដូរនឹងហាស

កៈ
ចុះអ៊ុំគិតថាតាំងពីក្មេងរហូតមកដល់ពេលនេះនឹងជីវិតរបស់អ៊ុំនឹងធ្លាប់ជួបទុកលំបាកអីគេខ្លះដែរអ៊ុំ?

ខៈ ថាអ៊ុំមិនថាម៉េចទេលំបាករហូតដែរនឹងហាសកូនហាសពីនៅក្មេងនឹងម៉ែឪកំសត់នឹង
ដល់ពេលដែរមានប្ដីទៅកំសត់នឹងហាស
ដល់ពេលដែរចាស់ទៅរាល់ថ្ងៃនឹងក៏នៅតែកំសត់ដែរនឹងហាស
កូនចៅវាអត់មានអ្នកធូរធាហាស

កៈ បាទអ៊ុំចុះអ៊ុំគិតថាជំនាន់លុនណុលនឹងអ៊ុំធ្លាប់ជួបទុកលំបាកអីគេដែរទៅ?

ខៈ ជំនាន់លុនណុលអ៊ុំនៅនោះទេតាអ៊ុំនៅនេះ
ដល់ពេលចឹងគាត់ជំលាសខ្លួនចឹងទៅចឹងគាត់ពិបាកអីចឹងអ៊ុំអត់មានដឹងទេណាស់

កៈ ប៉ុន្តែអ៊ុំនៅនោះនឹងអ៊ុំអត់មានបញ្ហាអីទេ?

ខៈ នៅនោះអត់មានបញ្ហាអីទេ

កៈ ចុះជំនាន់ពលពតនឹងអ៊ុំមានបញ្ហាអីទេអ៊ុំ?

ខៈ ជំនាន់ពលពតនឹងក៏អ៊ុំនៅនោះដែរ ចឹងអ៊ុំក៏មិនបានដឹងពីរឿងជំនាន់ពលពតដែរនឹង

កៈ អូ៎!!ចឹងជំនាន់ពលពតនឹងកម្ពុជាក្រោមនឹងអត់មានបញ្ហាអីទេណាអ៊ុំ?

ខៈ អត់មានទេអត់មានបញ្ហាអីទេកូន

កៈ អូ៎!!ចឹងអ៊ុំមានការរួចខ្លួនរហូតហើយចឹងណាអ៊ុំ?

ខៈ ចា៎!!នឹងហើយ

កៈ មកទាល់ឥឡូវនឹងក៏អ៊ុំអត់មានបញ្ហាអីដែរអ៊ុំពិបាកពេលដែរមានប្ដីទេណាអ៊ុំ?

ខៈ ចា៎!!នឹងហើយ

កៈ អូ៎!!បាទចុះពេលដែរអ៊ុំមានប្ដីនឹងអ៊ុំគិតថាអ៊ុំពិបាកអីគេខ្លះដែរទៅអ៊ុំ?

ខៈ ពីព្រោះអីគ្រួសាររបស់អ៊ុំជាអ្នកកំសត់

កៈ  អ៎ូ!!បាទអ៊ំ?

ខៈ  ហើយគ្រួសារខាងប្តីនឹងក៏កំសត់ដែរណាស់អូន

កៈ  បាទអ៊ំបាទចឹង?

ខៈ ដល់ពេលចឹងបានគ្នាអីចឹងទៅសុទ្ធតែខំប្រឹងហើយណាស់

កៈ  បាទអ៊ំបាទនឹងចឹង?

ខៈ  នឹងខំប្រឹងរកបានមានហូបនឹង

កៈ  បាទអ៊ំបាទ?

ខៈ  ខំប្រឹងរកខំប្រឹងលក់ដូរអីចឹងហាសណាស់

កៈ  បាទត្រូវហើយអ៊ំ?

ខៈ  តានឹងទៅស៊ីឈ្នួលគេ តាទៅស៊ីឈ្នួលគេដែរនឹង

កៈ  ប៉ុន្តែឥឡូវនឹងអ៊ំមានទុកលំបាកអីគេដែរអ៊ំ?

ខៈ  អ៊ុំវាអត់មានទុកអីទេប៉ុន្តែពេលដែរតាគាត់ស្លាប់បាត់ទៅយើងនឹង
ក៏នឹកឃើញអាណិតគាត់ដែរចឹងទៅណាស់

កៈ  បាទអ៊ំនឹង?

ខៈ  កាលគាត់នៅរស់គាត់មានការកំសត់កំរជាមួយយើងហាសណាស់

កៈ  បាទអ៊ំបាទ?

ខៈ
បានកំសត់កំរជាមួយយើងដល់ពេលទៅធ្វើចឹងបានលុយមកទិញបាយទិញម្ហូបអីស៊ីចឹងទៅ
ហើយយើងអត់បានហូបទូលាយអីនឹងគេទេណាស់កូន

កៈ  បាទអ៊ំបាទនឹង?

ខៈ  ចា៎!!អត់គ្មានហ៊ានហូបអីសំបូរឆ្ងាញ់ពិសារអីទេ

កៈ  បាទអ៊ំចឹងហោស?

ខ៖ ពេលណាកូនគេទៅរត់ម៉ូតូបានចឹងទៅ គេបានទិញគុយទាវអីផ្ញើរអោយមួយដងមួយយាមអីចឹងហាសចឹងបានហូបហើយនឹងហាស

ក៖ បាទចឹងបាទអ៊ុំ?

ខ៖ បើថាខ្លួនឯងនឹងអត់ហ៊ានទេអត់ទេខ្ញុំទិញហូបចឹង គាត់ទិញតែអង្ករហើយនឹងទិញម្ហូបនឹងហាស

ក៖ អូ៎!!ចឹងទេហោសអ៊ុំណា?

ខ៖ ចា៎!!នឹងហើយចឹង

ក៖ ចុះកាលពីនៅក្មេងនឹងអ៊ុំគិតថាអ៊ុំមានបញ្ហាលំបាកនឹងលំបាកអីគេដែរទៅអ៊ុំ លំបាកជីវភាពដែរមែនអ៊ុំ?

ខ៖ លំបាកជីវភាពនឹងអ៊ុំវាខ្សត់ខ្សោយមែនទែនតែម្តងនឹងហាស

ក៖ អូ៎!!បាទអ៊ុំបាទនឹង?

ខ៖ ចា៎!!នឹងហើយ

ក៖ ចុះអ៊ុំគិតថាអ៊ុំឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបណាដែរទៅអ៊ុំ?

ខ៖ អ៊ុំឆ្លងកាត់ការនៅក្មេងមកអ៊ុំឆ្លងកាត់បានប៉ុន្តែអ៊ុំចេះតែទ្រាំនឹង

ក៖ អ៊ុំចេះតស៊ូណាអ៊ុំ?

ខ៖ ចេះតែតស៊ូទៅចានឹងហើយ ចេះតែតស៊ូខំប្រឹងនឹង ទៅជួយម៉ែទៅជួយឪអោយម៉ែឪគាត់ធូរនឹង

ក៖ បាទអ៊ុំបាទ?

ខ៖ វាមិនបានថាអីទេគ្រាន់តែថាយើងទៅស៊ីឈ្នួលគេចឹងទៅបានកាលជំនាន់ណុងគេអោយនៅជាស្រូវ

ក៖ បាទអ៊ុំបាទ?

ខ៖ មួយឆ្នាំជំនាន់ណុងគេមិនថ្លឹងគីឡូទេគេហៅមួយតៅមួយថាំងហាសណាស់

ក៖ បាទត្រូវហើយអ៊ុំនឹង?

ខ៖ មួយឆ្នាំចឹងអ៊ុំធំពេញអ៊ុំមានកំលាំងចឹងមួយឆ្នាំចឹងអ៊ុំគេអោយបាន40ថាំងនឹងហាស

ក៖ បាន40ថាំងនឹងសំរាប់គេដោះដូរជាមួយយើងហោសអ៊ុំ?

ខ៖ បាន40ថាំងចឹងសំរាប់យើងធ្វើការអោយគេមួយឆ្នាំចឹងហាស

ក៖ អូ៎!!បាទអ៊ុំបាទនឹង?

ខ៖ ចឹងហាសកូនណាស់បាន40ថាំងអីចឹងទៅ

ក៖
បាទចុះអ៊ុំគិតថាពេលណាដែរអ៊ុំគិតថាជាពេលដែរសប្បាយនៅក្នុងឆាកជីវិតរបស់អ៊ុំដែរ?

ខ៖ សឹងទាំងថាអត់មានពេលសប្បាយទេ

ក៖ ចុះពេលដែរអ៊ុំការ
រឺមួយពេលដែរកូនរបស់អ៊ុំការនឹងអ៊ុំគិតថាសប្បាយទេពេលណុងហាសអ៊ុំ?

ខ៖ ពេលកូនការចឹងទៅអើរបានសប្បាយមួយគ្រាជាមួយកូនចឹងដែរទៅណាស់

ក៖ បាទអ៊ុំបាទនឹង?

ខ៖ ពេលការកូននឹងសឹងទាំងអស់មានទាំងលុយការផងនឹង

ក៖ អូ៎!!ចឹងហោសអ៊ុំហោស?

ខ៖
ចា៎!!ចឹងដល់ពេលដែររួចទៅហើយទៅដោះដូរប្តូរផ្ទះលុយមានសល់តិចតួចនឹងយកទៅការទៅ

ក៖ ការហើយចប់ហើយណាអ៊ុំ?

ខ៖ កូនអាទីមួយនឹងទៅចឹងចា

ក៖ បាទអ៊ុំបាទ?

ខ៖ ដល់ពេលទីពីរនឹងអ៊ុំខំធ្វើការងារចឹងទៅជួយគ្មានបានលុយជួយកូនច្រៀនទេ កូនគេការអស់ពីរបីពាន់ នឹងកូនអ្នកស្រែនឹង

ក៖ បាទអ៊ុំបាទនឹង?

ខ៖ ជួយបាន500$នឹង

ក៖ អូ៎!!អ៊ុំជួយគាត់ថែមទៀតហោសអ៊ុំ?

ខ៖ ចា៎!!នឹងហើយ

ក៖ ហើយអោយពួកគាត់ជួយចេញថែមដែរទៅ?

ខ៖ ចា៎!!ចេញដែរទៅ

ក៖
អូ៎!!បាទអ៊ុំចុះអ៊ុំគិតថាកាលពីក្មេងនឹងអ៊ុំធ្លាប់មានក្ដីស្រម៉ៃថាពេលដែរធំឡើងនឹងអ៊ុំចង់ធ្វើអី ទេ?

ខ៖ អ៊ុំស្រម៉ៃថាពេលដែរធំឡើងនឹងអ៊ុំរកស៊ីនឹងគេ មានផ្ទះមានសំបែងត្រឹមត្រូវល្អនឹងគេចឹង នៅចឹងហាស

ក៖ ចឹងហោសអ៊ុំហោស?

ខ៖ ហើយវាអត់បានដូចការស្រម៉ៃនឹងហាស

ក៖ អូ៎!!បាទ ចុះបើសិនជាចង់អោយអ៊ុំផ្ដែផ្ដាំនឹង
តើអ៊ុំចង់ផ្ដែផ្ដាំអីទៅកូនចៅជំនាន់ក្រោយៗរបស់អ៊ុំដែរ
ដើម្បីអោយគាត់អាចស្គាល់នឹងអាចដឹងអីដែរចឹងហាសអ៊ុំ?

ខ៖
អោយកូនចៅខំប្រឹងរកស៊ីទៅកុំអោយថ្ងៃក្រោយនឹងកុំអោយថ្ងៃក្រោយនឹងវាក្រលំបាកអីចឹង ទៅនឹង

ក៖ បាទអ៊ុំបាទនឹង?

ខ៖ ចា៎!!អោយខំប្រឹងទៅនឹង

ក៖ ចុះបើសិនជាចង់អោយពួកគាត់ជៀសវៀងវិញតើអ៊ុំចង់អោយពួកគាត់ជៀសវៀងអីគេវិញអ៊ុំ?

ខ៖ ជៀសវៀងកុំអោយក្រចឹងហាសអោយខំប្រឹងហាសណាស់កូន ជំនាន់ម៉ែឪនឹងពិបាកចឹងពេលដែរជំនាន់កូននឹង

ក៖ កុំអោយពិបាកទៀតណាអ៊ុំ?

ខ៖ នឹងវាចឹងកុំអោយពិបាកទៀតនឹងចា

ក៖ បាទអ៊ុំបាទ?

ខ៖ ចា៎ៗៗ!!នឹងហើយ

ក៖ ចឹងជាចុងក្រោយខ្ញុំអរគុណច្រើនអ៊ុំដែរបានពិភាក្សាដែរទាក់ទងពីប្រវត្តិមួយនឹងចឹងហាស

ខ៖ ចា៎!!នឹងហើយ

ក៖ បាទអរគុណច្រើនអ៊ុំ៕៕៕